**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១.៨២ ប្រ.កសក

# ប្រកាស
## ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវរូបសញ្ញាជាតិ ស្តីពីការអនុវត្តកសិកម្មល្អ

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ

-បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្រ្ត និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញប្រកាសលេខ ៣៣៤ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧ ស្តីពីការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម

-បានឃើញប្រកាសលេខ ០៩៩ កសក.ប ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើនូវវិធាននៃការអនុវត្តកសិកម្មល្អក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់

-យោងតាមភាពចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១..**

បង្កើត និងដាក់ឱ្យប្រើប្រាស់រូបសញ្ញាជាតិស្តីពីការអនុវត្តកសិកម្មល្អ (National GAP-logo) ដែលមានគំរូដូចបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២..**

រូបសញ្ញាជាតិស្តីពីការអនុវត្តកសិកម្មល្អ ប្រើសម្រាប់បញ្ជាក់ការទទួលស្គាល់លើផលិតផល និងសំបកវេចខ្ចប់នៃផលិតផលផ្លែឈើនិងបន្លែស្រស់ ដែលមានប្រភពចេញពីចម្ការ ឬកសិដ្ឋានដែលបានអនុវត្តត្រឹមត្រូវតាមវិធាននៃការអនុវត្តកសិកម្មល្អ។

រូបសញ្ញាជាតិស្តីពីការអនុវត្តកសិកម្មល្អ មិនត្រូវបានអនុវត្តចំពោះផលិតផលកសិកម្មផ្សេងទៀតក្រៅពីផលិតផលផ្លែឈើ និងបន្លែស្រស់ឡើយ។

**ប្រការ៣..**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលអនុវត្តការងារផលិតកម្មផ្លែឈើនិងបន្លែស្រស់ ឬធ្វើពាណិជ្ជកម្មផ្លែឈើ និងបន្លែស្រស់ និងមានបំណងប្រើរូបសញ្ញាជាតិ ស្តីពីការអនុវត្តកសិកម្មល្អ ដោយបិទនៅលើផលិតផលរបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំនៅអគ្គនាយកដ្ឋានកសិកម្ម ដើម្បីចុះឈ្មោះ និងស្នើសុំវាយតម្លៃការងារផលិតកម្មនៅក្នុងចម្ការ ឬកសិដ្ឋានរបស់ខ្លួន។

អគ្គនាយកដ្ឋានកសិកម្ម ត្រូវចាត់តាំងភ្នាក់ងារបច្ចេកទេស ដើម្បីចុះពិនិត្យ និងវាយតម្លៃលើការងារផលិតកម្ម ផ្លែឈើ និងបន្លែស្រស់ តាមការស្នើសុំរបស់ម្ចាស់ចម្ការ ឬកសិដ្ឋាន។

គំរូពាក្យស្នើសុំវាយតម្លៃការអនុវត្តកសិកម្មល្អ ត្រូវកំណត់ដោយអគ្គនាយកដ្ឋានកសិកម្ម។

**ប្រការ៤..**

ម្ចាស់ចម្ការ ឬកសិដ្ឋានអាចទទួលបាននូវវិញ្ញាបនបត្រអនុលោមភាពតាមវិធាន នៃការអនុវត្តកសិកម្មល្អ ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម ក្នុងករណីការងារផលិតកម្មដែលបានអនុវត្តចាប់ពីដំណាក់កាលរៀបចំផលិតកម្មរហូតដល់ដំណាក់កាលក្រោយពេលប្រមូលផល ត្រូវបានវាយតម្លៃ និងសម្រេចដោយអគ្គនាយកដ្ឋានកសិកម្ម ថាមានអនុលោមភាពស្របតាមវិធាននៃការអនុវត្តកសិកម្មល្អ។

**ប្រការ៥..**

រាល់ផលិតផលផ្លែឈើ និងបន្លែស្រស់ដែលចេញពីចម្ការ ឬកសិដ្ឋាន ដែលទទួលបានវិញ្ញាបនបត្រអនុលោមភាពតាមវិធាននៃការអនុវត្តកសិកម្មល្អ ត្រូវបានអនុញ្ញាតឱ្យបិទរូបសញ្ញាជាតិនៃការអនុវត្តកសិកម្មល្អជាសំគាល់ ដើម្បីបញ្ជាក់ថាជាផលិតផលដែលត្រូវបានត្រួតពិនិត្យ វាយតម្លៃ និងទទួលស្គាល់ដោយភ្នាក់ងារមានសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានកសិកម្ម ដោយអនុលោមតាមវិធាននៃការអនុវត្តកសិកម្មល្អ។

**ប្រការ៦..**

អគ្គនាយកដ្ឋានកសិកម្មត្រូវគ្រប់គ្រងការប្រើប្រាស់រូបសញ្ញាជាតិស្តីពីការអនុវត្តកសិកម្មល្អ ដែលត្រូវបិទលើផលិតផលផ្លែឈើនិងបន្លែស្រស់ដែលបានទទួលស្គាល់ប្រភពចេញពីចម្ការ ឬកសិដ្ឋាន ដែលបានអនុលោមតាមវិធាននៃការអនុវត្តកសិកម្មល្អ។

**ប្រការ៧..**

ម្ចាស់ចម្ការឬកសិដ្ឋាន ត្រូវទទួលបន្ទុកលើការបង់កម្រៃសេវាសាធារណៈលើការងារវាយតម្លៃការអនុវត្តកសិកម្មល្អ ដូចខាងក្រោម៖

-ការងារវាយតម្លៃលើផលិតកម្មផ្លែឈើនិងបន្លែស្រស់ ដែលអនុវត្តដោយក្រុមភ្នាក់ងារបច្ចេកទេសរបស់អគ្គនាយកដ្ឋានកសិកម្ម

-ការចេញវិញ្ញាបនបត្រអនុលោមភាពតាមវិធាន នៃការអនុវត្តកសិកម្មល្អ

-រូបសញ្ញាជាតិស្តីពីការអនុវត្តកសិកម្មល្អ តាមបរិមាណជាក់ស្តែងដែលស្នើសុំ។

កម្រៃសេវាសាធារណៈលើការងារវាយតម្លៃការអនុវត្តកសិកម្មល្អ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៨..**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥..**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត វ៉េង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៩
- ឯកសារ កាលប្បវត្តិ